# សេចក្តីថ្លែងការណ៍ភ្នំពេញ
# អំពីការអនុម័តសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន

**យើង** *ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃរដ្ឋជាសមាជិករបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី ២១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

**អះអាងជាថ្មី** *លើការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក៏ដូចជាគោលបំណង និងគោលការណ៍ដែលមានចែងក្នុងធម្មនុញ្ញអាស៊ាន ក្នុងនោះមានគោលការណ៍ប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិបាលកិច្ចល្អ*

**បញ្ជាក់ឡើងវិញ** *លើការប្តេជ្ញាចិត្តរបស់អាស៊ាន និងរដ្ឋជាសមាជិកអាស៊ានចំពោះធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស សេចក្តីប្រកាសនិងកម្មវិធីសកម្មភាពទីក្រុងវីយែន និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិឯទៀតដែលរដ្ឋជាសមាជិកអាស៊ានជាភាគី ក៏ដូចជាសេចក្តីប្រកាសដទៃទៀតរបស់អាស៊ានទាក់ទងនឹងសិទ្ធិមនុស្ស*

**ទទួលស្គាល់** *សារៈសំខាន់នៃតួនាទីរបស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានទទួលបន្ទុកសិទ្ធិមនុស្ស (គ.អ.អ.ស.ម) ជាស្ថាប័នប្រកបដោយវិសាលភាពទូលំទូលាយទទួលខុសត្រូវក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនៅក្នុងអាស៊ាន ដែលរួមចំណែកដល់ការស្ថាបនាសហគមន៍អាស៊ានមួយដែលផ្តោតលើប្រជាជន និងជាយានសម្រាប់ការអភិវឌ្ឍនិងយុត្តិធម៌សង្គម ការសំរេចឱ្យបានទាំងស្រុងនូវសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការទទួលបានគុណភាពនៃជីវិតដ៏ល្អប្រសើរ សំរាប់ប្រជាជនអាស៊ាន*

**លើកសរសើរជាសាធារណៈ** *ចំពោះ គ.អ.អ.ស.ម លើការរៀបចំតាក់តែងសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សដ៏ពិស្តារ ដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពជំនាញអាស៊ាននិងភាគីពាក់ព័ន្ធដទៃទៀត*

**ទទួលស្គាល់** *ការរួមចំណែកប្រកបដោយអត្ថន័យរបស់អង្គភាពជំនាញអាស៊ាន និងភាគីពាក់ព័ន្ធដទៃៗទៀតក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្សនៅក្នុងអាស៊ាន និងលើកទឹកចិត្តឱ្យបន្តការចូលរួម និងផ្លាស់ប្តូរយោបល់ជាមួយ គ.អ.អ.ស.ម*

**ហេតុដូច្នេះ**

*១. **អនុម័ត** សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន (ស.ស.ម.អ.)*

*២. **បញ្ជាក់** អំពីការប្តេជ្ញាចិត្តរបស់យើងចំពោះការអនុវត្តន៍ឱ្យបានពេញលេញនូវសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ដើម្បីជំរុញការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សក្នុងតំបន់ និង*

៣. ***បញ្ជាក់បន្ថែមជាថ្មីម្តងទៀត*** *ការតាំងចិត្តរបស់យើងសំដៅធានាថាការអនុវត្ត ស.ស.ម.អ. នេះ ត្រូវតែស្របនឹងឆន្ទៈរបស់យើងចំពោះធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស សេចក្តីប្រកាសនិងកម្មវិធីសកម្មភាពទីក្រុងវីយែន និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិឯទៀតដែលរដ្ឋជាសមាជិកអាស៊ានជាភាគី ក៏ដូចជាសេចក្តីប្រកាសនិងលិខិតុបករណ៍ដទៃទៀតរបស់អាស៊ានទាក់ទងនឹងសិទ្ធិមនុស្ស ។*

***ធ្វើនៅ*** *រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ដប់ប្រាំបី នៃខែ វិច្ឆិកា ក្នុងឆ្នាំ ពីរពាន់ដប់ពីរ ក្នុងច្បាប់ដើមតែមួយគត់ជាភាសាអង់គ្លេស។*

*ជ.ប្រ៊ុយណេ ដារូសាឡឹម*

**ហាជី ហាសាណាល បូលកៀហ**

*ព្រះចៅស៊ុលតង់ នៃប្រ៊ុយណេដារូសាឡឹម*

*ជ.ព្រះរាជាណាចក្រកម្ពុជា*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*នាយករដ្ឋមន្ត្រី*

*ជ.សាធារណៈរដ្ឋឥណ្ឌូណេស៊ី*

**ស៊ូស៊ីឡូ បាំបាំង យូដូយ៉ូណូ**

*ប្រធានាធិបតី*

*ជ.សាធារណៈរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ*

**ថុងស៊ីង ថាំម៉ាវង្ស**

*នាយករដ្ឋមន្ត្រី*

*ជ.ម៉ាឡេស៊ី*

**ដាតុ ស្រ៊ី ម៉ូដ ណាជីប ទុន អាប់ឌុល រ៉ាហ្សាក**

*នាយករដ្ឋមន្ត្រី*

*ជ.សាធារណៈរដ្ឋសហភាពមីយ៉ានម៉ា*

**យូ ធៀន សៀន**

*ប្រធានាធិបតី*

*ជ.សាធារណៈរដ្ឋភីលីពីន*

**បេនីខហ្គោ ស. អាគីណូ III**

*ប្រធានាធិបតី*

*ជ.សាធារណៈរដ្ឋសិង្ហបុរី*

**លី សៀន លុង**

*នាយករដ្ឋមន្ត្រី*

*ជ.ព្រះរាជាណាចក្រថៃ*

**យីនឡាក់ ស៊ីណាវ៉ាត្រា**

*នាយករដ្ឋមន្ត្រី*

*ជ.សាធារណៈរដ្ឋសង្គមនិយមវៀតណាម*

**ង្វៀន តាន់ យុង**

*នាយករដ្ឋមន្ត្រី*

# សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន

**យើង** ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ដែលតទៅនេះហៅកាត់ថា "**អាស៊ាន**") រួមមានប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី ២១ នៅព្រះរាជាណាចក្រកម្ពុជា ។

**បញ្ជាក់អះអាងម្តងទៀត** អំពីការប្រកាន់ខ្ជាប់របស់យើងទាំងអស់គ្នាចំពោះគោលបំណង និងគោលការណ៍របស់អាស៊ាន ដូចដែលមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន ជាពិសេសការគោរព ការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ព្រមទាំងគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិបាលកិច្ចល្អ ។

**បញ្ជាក់អះអាងបន្ថែមម្តងទៀត** អំពីការប្តេជ្ញាចិត្តចំពោះសេចក្តីប្រកាសជាសកលអំពីសិទ្ធិមនុស្ស ធម្មនុញ្ញសហប្រជាជាតិ សេចក្តីថ្លែងការណ៍និងកម្មវិធីសកម្មភាពទីក្រុងវីយែន និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀតដែលរដ្ឋជាសមាជិកអាស៊ានជាភាគី ។

**បញ្ជាក់អះអាងម្តងទៀតផងដែរ** នូវសារៈសំខាន់នៃកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ានក្នុងការលើកកម្ពស់សិទ្ធិមនុស្ស ក្នុងនោះមានសេចក្តីប្រកាសស្តីពីការលើកកម្ពស់ស្ត្រីក្នុងតំបន់អាស៊ាន និងសេចក្តីប្រកាសស្តីពីការលុបបំបាត់អំពើហឹង្សាប្រឆាំងស្ត្រីក្នុងតំបន់អាស៊ាន ។

**មានការជឿជាក់ថា** សេចក្តីប្រកាសនេះនឹងរួមចំណែកបង្កើតក្របខណ្ឌកិច្ចសហប្រតិបត្តិការសិទ្ធិមនុស្សនៅក្នុងតំបន់ និងចូលរួមចំណែកក្នុងដំណើរការកសាងសហគមន៍អាស៊ាន ។

**ប្រកាសដូចតទៅនេះ**

## គោលការណ៍ទូទៅ

១. មនុស្សគ្រប់រូបកើតមកមានសេរីភាពនិងសមភាពក្នុងសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ។ មនុស្សគ្រប់រូបមានហេតុផលនិងសតិសម្បជញ្ញៈ និងគួរប្រព្រឹត្តចំពោះគ្នានឹងគ្នាដោយស្មារតីមនុស្សធម៌ ។

២. មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានសិទ្ធិនិងសេរីភាព ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការបែងចែកអំពីជាតិសាសន៍ ភេទ អាយុ ភាសា សាសនា មតិនយោបាយឬមតិឯទៀត ប្រភពដើមនៃជាតិឬសង្គម ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពកំណើត ស្ថានភាពពិការភាព ឬស្ថានភាពអ្វីផ្សេងទៀតឡើយ ។

៣. មនុស្សម្នាក់ៗ មានសិទ្ធិនៃការទទួលស្គាល់ថាជាមនុស្សនៅគ្រប់ទីកន្លែងចំពោះមុខច្បាប់ ។ មនុស្សម្នាក់ៗ ស្មើគ្នានៅចំពោះមុខច្បាប់ ។ មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានការការពារស្មើគ្នាពីច្បាប់ដោយគ្មានការរើសអើង ។

៤. សិទ្ធិរបស់ស្ត្រី កុមារ ជនចាស់ជរា ជនមានពិការភាព ពលករទេសន្តរប្រវេសន៍ និងក្រុមជនងាយរងគ្រោះ និងក្រុមជនដែលគេបោះបង់ចោលគឺជាផ្នែករួមបញ្ចូលដែលមិនអាចដកហូត និងមិនអាចបំបែកបានពីសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ។

៥. មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានដំណោះស្រាយដ៏មានប្រសិទ្ធិភាព និងអាចអនុវត្តបាន ដែលកំណត់ដោយតុលាការឬអាជ្ញាធរមានសមត្ថកិច្ច ចំពោះទង្វើដែលរំលោភបំពានលើសិទ្ធិដែលខ្លួនទទួលបានពីរដ្ឋធម្មនុញ្ញនិងពីច្បាប់ ។

៦. ការប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានត្រូវតែមានការថ្លឹងថ្លែង ជាមួយនឹងការអនុវត្តភារកិច្ចផ្សេងៗដែលពាក់ព័ន្ធ ដូចដែលមនុស្សម្នាក់ៗ មានការទទួលខុសត្រូវចំពោះមនុស្សដទៃទៀត ចំពោះសហគមន៍ និងសង្គមដែលគេរស់នៅ ។ នេះគឺជាការទទួលខុសត្រូវដ៏ចម្បងបំផុតរបស់រដ្ឋជាសមាជិកអាស៊ាន ក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងឡាយ ។

៧. សិទ្ធិមនុស្សទាំងអស់មានតម្លៃជាសកល មិនអាចបំបែកចេញពីគ្នាបាន មានការពឹងពាក់អាស្រ័យគ្នា និងមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានទាំងអស់ដែលមានចែងនៅក្នុងសេចក្ដីប្រកាសនេះ ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវនិងស្មើភាព ដោយមានជំហរនិងការយកចិត្តទុកដាក់ដូចគ្នា ។ ទន្ទឹមនឹងនេះ ការទទួលបាននិងការអនុវត្តសិទ្ធិមនុស្សត្រូវគិតពិចារណាអំពីបរិបទតំបន់និងជាតិ ដោយយកចិត្តទុកដាក់ពីទិដ្ឋភាពផ្សេងគ្នានៃនយោបាយ សេដ្ឋកិច្ច ច្បាប់ សង្គម វប្បធម៌ ប្រវត្តិសាស្ត្រ និងសាសនា ។

៨. សិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋានរបស់មនុស្សម្នាក់ៗ ត្រូវអនុវត្តដោយមានការពិចារណាត្រឹមត្រូវអំពី សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃ ។ ការប្រើប្រាស់សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាននេះ មានព្រំដែនដែលកំណត់ដោយច្បាប់ ដើម្បីធានាការទទួលស្គាល់ត្រឹមត្រូវចំពោះសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានរបស់អ្នកដទៃ និងដើម្បីបំពេញតម្រូវការពិតប្រាកដខាងសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ សុវត្ថិភាពសាធារណៈ សីលធម៌សាធារណៈ ក៏ដូចជាសុខុមាលភាពជាទូទៅរបស់ប្រជាជនក្នុងសង្គមប្រជាធិបតេយ្យ ។

៩. ដើម្បីទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដូចមានចែងនៅក្នុងសេចក្ដីប្រកាសនេះ ត្រូវប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍ដូចតទៅ គោលការណ៍មិនលម្អៀង គោលការណ៍ព្រឹត្តិហេតុ ភាពមិនរើសមុខ ការមិនរើសអើង ការមិនប្រឈមមុខគ្នា និងជៀសវាងគោលការណ៍ស្តង់ដារពីរ និងនយោបាយនីយកម្ម ។ ដំណើរការខាងលើនេះត្រូវយកចិត្តទុកដាក់ពីការចូលរួម និងការរួមចំណែករបស់ប្រជាជនប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

## សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

១០. រដ្ឋជាសមាជិកអាស៊ាន ទទួលស្គាល់សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយទាំងអស់ដែលមាននៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ។ ជាពិសេសរដ្ឋជាសមាជិកអាស៊ាន សូមធ្វើការទទួលស្គាល់សិទ្ធិនិងសេរីភាពជាមូលដ្ឋានដូចខាងក្រោមនេះ៖

១១. មនុស្សម្នាក់ៗ មានសិទ្ធិមួយដែលជាសិទ្ធមិនអាចខ្វះបានគឺសិទ្ធិក្នុងការរស់រានមានជីវិតដែលត្រូវបានការពារដោយច្បាប់ ។ គ្មានមនុស្សណាម្នាក់អាចត្រូវដកហូតយកសិទ្ធិរស់រានមានជីវិតបានឡើយ លើកលែងតែច្បាប់អនុញ្ញាត ។

១២. មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានសេរីភាពនិងសន្តិសុខផ្ទាល់ខ្លួន ។ គ្មានមនុស្សណាម្នាក់អាចត្រូវឃាត់ខ្លួន ស្វែងរក ឃុំឃាំង ការចាប់បង្ខំតាមអំពើចិត្ត ឬទម្រង់ណាមួយនៃការដកហូតសេរីភាពតាមអំពើចិត្តនោះឡើយ ។

១៣. គ្មានមនុស្សណាម្នាក់ត្រូវស្ថិតក្រោមទម្រង់ណាមួយនៃសេវគតិភាពឬទាសភាព ឬជាកម្មវត្ថុនៃការរត់ពន្ធមនុស្ស ឬការជួញដូរមនុស្ស រាប់បញ្ចូលទាំងការរត់ពន្ធឬជួញដូរមនុស្សក្នុងគោលបំណងនៃការជួញដូរសរីរាង្គ ។

១៤. គ្មានមនុស្សណាម្នាក់ត្រូវស្ថិតក្រោមការធ្វើទណ្ឌកម្ម ឬការប្រព្រឹត្តិមកលើ ឬការដាក់ទោសដែលមានលក្ខណៈឃោរឃៅ អមនុស្សធម៌ ឬ បន្ទាបបន្ថោកនោះឡើយ ។

១៥. មនុស្សម្នាក់ៗ មានសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ និងតាំងទីលំនៅក្នុងព្រំដែននៃរដ្ឋនីមួយៗ ។ មនុស្សគ្រប់រូបមានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសកំណើតរបស់ខ្លួនផង និងមានសិទ្ធិធ្វើមាតុភូមិនិវត្តទៅប្រទេសកំណើតរបស់ខ្លួនវិញ ។

១៦. មនុស្សម្នាក់ៗ មានសិទ្ធិក្នុងការស្វែងរក និងទទួលបានសិទ្ធិជ្រកកោននៅក្នុងរដ្ឋផ្សេងទៀតដោយស្របទៅតាមច្បាប់នៃរដ្ឋនោះ និងកិច្ចព្រមព្រៀងអន្តរជាតិដែលអាចអនុវត្តបាន ។

១៧. មនុស្សម្នាក់ៗ មានសិទ្ធិកម្មសិទ្ធិ ប្រើប្រាស់ ចាត់ចែង និងបរិច្ចាគកម្មសិទ្ធិដែលបានទទួលដោយស្របច្បាប់ តែម្នាក់ឯងឬជាមួយអ្នកដទៃទៀត ។ គ្មានមនុស្សណាម្នាក់ត្រូវបានដកហូតកម្មសិទ្ធិនេះតាមអំពើចិត្តបានឡើយ ។

១៨. មនុស្សម្នាក់ៗ មានសិទ្ធិមានសញ្ជាតិដែលមានចែងក្នុងច្បាប់ ។ គ្មានមនុស្សណាម្នាក់ត្រូវបានដកហូតតាមអំពើចិត្តនូវសញ្ជាតិនេះ ឬត្រូវបានបដិសេធតាមអំពើចិត្តនូវសិទ្ធិក្នុងការផ្លាស់ប្តូរសញ្ជាតិឡើយ ។

១៩. គ្រួសារ ជាធាតុធម្មជាតិនិងជាធាតុមូលដ្ឋានរបស់សង្គម មានសិទ្ធិទទួលបានការការពារដោយសង្គម និងដោយរដ្ឋជាសមាជិកអាស៊ាននីមួយៗ ។ បុរសនិងស្ត្រីដែលពេញវ័យមានសិទ្ធិរៀបអាពាហ៍ពិពាហ៍លើមូលដ្ឋាននៃសេរីភាព

និងការព្រមព្រៀងពេញលេញរបស់ខ្លួន ដើម្បីបង្កើតគ្រួសារមួយ និងផ្តាច់ចំណងអាពាហ៍ពិពាហ៍ដូចដែលមានចែងដោយច្បាប់ ។

២០. (១) មនុស្សម្នាក់ៗ ដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់ក្នុងការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាសាធារណៈដោយការជំនុំជម្រះក្តីដែលមានសមត្ថកិច្ច ឯករាជ្យភាព និងភាពមិនលម្អៀង ដែលក្នុងការជម្រះក្តីនេះជនជាប់ចោទត្រូវបានធានាថាមានសិទ្ធិទទួលបានការការពារ ។

(២) គ្មានមនុស្សណាម្នាក់ ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ចំពោះអំពើឬការខកខានណាមួយដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌ ស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ ក្នុងខណៈពេលប្រព្រឹត្តនោះឡើយ ហើយគ្មានមនុស្សណាម្នាក់ត្រូវទទួលរងការដាក់ទោសធ្ងន់ធ្ងរចំពោះបទល្មើសណាមួយ លើសពីទោសដែលមានចែងដោយច្បាប់នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តឡើយ ។

(៣) គ្មានមនុស្សណាម្នាក់ ត្រូវទទួលការកាត់ទោសឬដាក់ទោសជាថ្មីទេ សម្រាប់បទល្មើសដែលបុគ្គលនោះត្រូវបានតុលាការផ្តន្ទាទោសឬលើកលែងការចោទប្រកាន់ជាស្ថាពររួចហើយ ដោយអនុលោមតាមច្បាប់និងនីតិវិធីព្រហ្មទណ្ឌនៃរដ្ឋជាសមាជិកនីមួយៗរបស់អាស៊ាន ។

២១. មនុស្សម្នាក់ៗ មានសិទ្ធិរួចផុតពីការជ្រៀតជ្រែកតាមអំពើចិត្តលើភាពជាឯកជន គ្រួសារ ផ្ទះសំបែង ឬការឆ្លើយឆ្លងរួមទាំងទិន្នន័យផ្ទាល់ខ្លួនផង ឬមានសិទ្ធិរួចផុតពីការវាយប្រហារលើកិត្តិយសនិងកេរ្តិ៍ឈ្មោះ ។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារតាមផ្លូវច្បាប់ទប់ទល់នឹងការជ្រៀតជ្រែក ឬ ការវាយប្រហារបែបនេះ ។

២២. មនុស្សម្នាក់ៗ មានសិទ្ធិសេរីភាពក្នុងការគិត សតិសម្បជញ្ញៈ និងសាសនា ។ រាល់ទម្រង់ទាំងអស់នៃការមិនអត់ឱន ការរើសអើង និងការញុះញង់ឲ្យមានការស្អប់ខ្ពើមលើផ្នែកសាសនានិងជំនឿនានាត្រូវលុបបំបាត់ចោល ។

២៣. មនុស្សម្នាក់ៗ មានសិទ្ធិសេរីភាពនៃមតិ និងសិទ្ធិសេរីភាពក្នុងការសម្តែងមតិ រួមមានសេរីភាពក្នុងការប្រកាន់មតិដោយគ្មានការ ជ្រៀតជ្រែក និងមានសិទ្ធិស្វែងរក ទទួលយក និងចែកចាយព័ត៌មាន ដោយផ្ទាល់មាត់ឬជាលាយល័ក្ខណ៍អក្សរ ឬ តាមរយៈបណ្តាញព័ត៌មានផ្សេងទៀតណាមួយដែលជាជម្រើសរបស់ខ្លួន ។

២៤. មនុស្សម្នាក់ៗ មានសិទ្ធិសេរីភាព ក្នុងការប្រជុំដោយសន្តិវិធី ។

២៥. (១) មនុស្សម្នាក់ៗ ដែលជាពលរដ្ឋនៃប្រទេសរបស់ខ្លួន មានសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ឬមិនផ្ទាល់តាមរយៈតំណាងដែលត្រូវបានបោះឆ្នោតជ្រើសរើសតាមបែបប្រជាធិបតេយ្យ ស្របតាមច្បាប់របស់ប្រទេស ។

(២) ពលរដ្ឋម្នាក់ៗ មានសិទ្ធិបោះឆ្នោតតាមកាលកំណត់ច្បាស់លាស់ និងពិតប្រាកដដែលជាការបោះឆ្នោតជាសកលនិងស្មើភាព និងតាមរយៈការបោះឆ្នោតជាសម្ងាត់ដែលអាចធានាការសម្តែងឆន្ទៈដោយសេរីរបស់អ្នកបោះឆ្នោតស្របតាមច្បាប់ជាតិ ។

## សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

២៦. រដ្ឋជាសមាជិកអាស៊ានទទួលស្គាល់ សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ទាំងឡាយដែលមានចែងនៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ។ ជាពិសេស រដ្ឋជាសមាជិកអាស៊ានទទួលស្គាល់សិទ្ធិទាំងឡាយដូចខាងក្រោមៈ

២៧. (១) មនុស្សម្នាក់ៗ មានសិទ្ធិបំពេញការងារ ជ្រើសរើសការងារដោយសេរី ទទួលបានល័ក្ខខ័ណ្ឌការងារត្រឹមត្រូវសមរម្យនិងល្អប្រសើរ និងទទួលបានការឧបត្ថម្ភគាំទ្រទៅតាមគម្រោងជំនួយសម្រាប់អ្នកគ្មានការងារធ្វើ ។

(២) មនុស្សម្នាក់ៗ មានសិទ្ធិបង្កើតសហជីព និងចូលរួមក្នុងសហជីពតាមជម្រើសរបស់ខ្លួនដើម្បីការពារផលប្រយោជន៍របស់ខ្លួនស្របទៅតាមច្បាប់ជាតិនិងវិធានផ្សេងៗ ។

(៣) ពុំមានកុមារឬមនុស្សវ័យក្មេងណាម្នាក់ត្រូវបានកេងប្រវ័ញ្ចខាងផ្នែកសេដ្ឋកិច្ចនិងសង្គមឡើយ ។ ជនណាដែលជួលកុមារនិងមនុស្សវ័យក្មេងឱ្យធ្វើការងារដែលប៉ះពាល់ដល់បញ្ញាស្មារតីឬសុខភាពរបស់ពួកគេ ដែលមានគ្រោះថ្នាក់ដល់អាយុជីវិត ឬដែលអាចរំខានដល់ការអភិវឌ្ឍជាប្រក្រតីរបស់គេ ដូចជាការសិក្សាជាដើមនោះ ត្រូវផ្តន្ទាទោសតាមច្បាប់ ។ រដ្ឋជាសមាជិកអាស៊ានគួរកំណត់កម្រិតអាយុ ហើយការជួលពលកម្មកុមារដែលមានអាយុតិចជាងនេះ ត្រូវបានហាមឃាត់និងផ្តន្ទាទោសតាមច្បាប់ ។

២៨. មនុស្សម្នាក់ៗ មានសិទ្ធិមានកម្រិតជីវភាពគ្រប់គ្រាន់សម្រាប់ខ្លួនឯងនិងគ្រួសារ ដូចជាៈ

ក. សិទ្ធិមានម្ហូបអាហារគ្រប់គ្រាន់និងស្របតាមលទ្ធភាព សិទ្ធិរួចផុតពីភាពអត់ឃ្លាន និងសិទ្ធិទទួលបានម្ហូបអាហារដែលមានសុវត្ថិភាពនិងមានអាហារូបត្ថម្ភ

ខ. សិទ្ធិមានសម្លៀកបំពាក់

គ. សិទ្ធិមានលំនៅដ្ឋានសមរម្យនិងស្របតាមលទ្ធភាព

ឃ. សិទ្ធិទទួលបានការថែទាំសុខភាពនិងសេវាសង្គមចាំបាច់នានា

ង. សិទ្ធិទទួលបានទឹកពិសារប្រកបដោយសុវត្ថិភាព និងអនាម័យ

ច. សិទ្ធិទទួលបានបរិស្ថានប្រកបដោយសុវត្ថិភាព ភាពបរិសុទ្ធ និងចីរភាព ។

២៩. (១) មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានស្តង់ដាសុខភាពខាងផ្លូវកាយ ខាងផ្លូវចិត្ត និងសុខភាពបន្តពូជដ៏ល្អប្រសើរបំផុតដែលអាចទទួលបាន មានសិទ្ធិទទួលបានសេវាថែទាំសុខភាពជាមូលដ្ឋានសមស្របតាមលទ្ធភាព និងមានសិទ្ធិទទួលបានការព្យាបាលនៅកន្លែងវេជ្ជសាស្ត្រនានា ។

(២) រដ្ឋជាសមាជិកអាស៊ានត្រូវបង្កើតបរិយាកាសល្អប្រសើរដើម្បីជម្នះការមាក់ងាយ ការមិនប្រាស្រ័យទាក់ទង ការ មើលស្រាល និងការរើសអើង ក្នុងការបង្ការ ការព្យាបាល ការថែទាំនិងគាំទ្រចំពោះប្រជាជនដែលមានជម្ងឺធ្ងន់ នានា ដូចជាមេរោគអេដស៍និងជម្ងឺអេដស៍ជាដើម ។

៣០. (១) មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គមប្រសិនបើមាន ដែលជួយគាត់ក្នុងការធានានូវមធ្យោបាយសម្រាប់ការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរនិងសមរម្យ ។

(២) ការគាំពារជាពិសេសត្រូវផ្តល់ជូនទៅដល់មាតាក្នុងអំឡុងពេលសមស្របដូចបានចែងក្នុងច្បាប់ជាតិនិងវិធានផ្សេងៗ មុននិងក្រោយពេលសម្រាលបុត្រ ។ ក្នុងអំឡុងពេលពិសេសនេះ ម្តាយដែលកំពុងបំពេញការងារ ត្រូវទទួលបានការឈប់សម្រាកដោយទទួលបានប្រាក់បៀវត្សន៍ឬការឈប់សម្រាកដោយមានរបបសន្តិសុខសង្គមគ្រប់គ្រាន់ ។

(៣) ទាំងមាតុភាព និងកុមារភាពផងត្រូវទទួលបានការថែទាំនិងជំនួយជាពិសេស ។ កុមារគ្រប់រូបទោះកើតមកមានខាន់ស្លាក្តីឬគ្មានខាន់ស្លាក្តីត្រូវទទួលបានការគាំពារសង្គមនេះដូចគ្នា ។

៣១. (១) មនុស្សម្នាក់ៗ មានសិទ្ធិទទួលបានការអប់រំ ។

(២) ការអប់រំនៅកម្រិតបឋមសិក្សាគឺជាកាតព្វកិច្ច និងត្រូវផ្តល់ជូនសម្រាប់ទាំងអស់គ្នាដោយឥតគិតថ្លៃ ។ ការអប់រំនៅកម្រិតមធ្យមសិក្សាក្នុងទម្រង់ផ្សេងៗ ត្រូវផ្តល់ជូននិងអាចទទួលបានសម្រាប់សិស្សទាំងអស់តាមរយៈមធ្យោបាយសមស្របនានា ។ ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈត្រូវផ្តល់ជូនជាទូទៅ ។ ការអប់រំកម្រិតឧត្តមសិក្សាត្រូវផ្តល់ជូនដោយស្មើភាពគ្នាចំពោះទាំងអស់គ្នាដោយផ្អែកទៅលើមូលដ្ឋានសមត្ថភាព ។

(៣) ការអប់រំមានគោលដៅអភិវឌ្ឍយ៉ាងពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ ការអប់រំត្រូវពង្រឹងការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានដទៃៗ ទៀតនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ។ លើសពីនេះទៅទៀត ការអប់រំត្រូវផ្តល់លទ្ធភាពឱ្យមនុស្សគ្រប់រូបអាចចូលរួមយ៉ាងមានប្រសិទ្ធិភាពនៅក្នុងសង្គមរបស់ខ្លួន លើកកម្ពស់ការយល់ដឹង ការយោគយល់អធ្យាស្រ័យនិងមិត្តភាពក្នុងចំណោមប្រជាជាតិ ជាតិសាសន៍និងក្រុមសាសនា និងមានគោលដៅពង្រីកនូវសកម្មភាពនានារបស់សមាគមអាស៊ានដើម្បីរក្សាសន្តិភាព ។

៣២. មនុស្សម្នាក់ៗ ទោះម្នាក់ឯងក្តីឬជាក្រុមក្តី មានសិទ្ធិចូលរួមដោយសេរីនៅក្នុងជីវិតវប្បធម៌ មានសិទ្ធិទទួលបានការរីករាយពីសិល្បៈ និងទទួលបានផលប្រយោជន៍ពីការរីកចម្រើននិងការប្រើប្រាស់ខាងវិទ្យាសាស្ត្រ និងមានសិទ្ធិទទួលបានការការពារអត្ថប្រយោជន៍ទាំងផ្នែកស្មារតីនិងសម្ភារៈដែលបានមកពីស្នាដៃវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈដែលខ្លួនជាអ្នកបង្កើតឬជាអ្នកនិពន្ធ ។

៣៣. រដ្ឋជាសមាជិកអាស៊ានត្រូវមានវិធានការផ្សេងៗ ដោយប្រើឱ្យអស់លទ្ធភាពនូវធនធានដែលខ្លួនមាន ទោះបីដោយខ្លួនឯងក្តីឬតាមរយៈជំនួយសហប្រតិបត្តិការតំបន់ និងអន្តរជាតិក្តី ជាពិសេសទាក់ទងនឹងវិស័យសេដ្ឋកិច្ច និងបច្ចេកវិទ្យា ដើម្បីទទួលនិងអនុវត្តសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ដូចដែលបានទទួលស្គាល់ក្នុងសេចក្តីប្រកាសនេះ ។

៣៤. រដ្ឋជាសមាជិកអាស៊ានអាចកំណត់ពីវិសាលភាព ដែលខ្លួនអាចធានាសិទ្ធិសេដ្ឋកិច្ចនិងសង្គមដូចមានចែងក្នុងសេចក្តីប្រកាសនេះ ជូនជនទាំងឡាយដែលមិនមែនប្រជាជាតិខ្លួន ដោយពិចារណាហ្មត់ចត់ពីសិទ្ធិមនុស្ស និងការរៀបចំចាត់ចែងនិងធនធានផ្សេងៗនៃសេដ្ឋកិច្ចជាតិរបស់ពួកគេ ។

**សិទ្ធិទទួលបានការអភិវឌ្ឍ**

៣៥. សិទ្ធិទទួលបានការអភិវឌ្ឍគឺជាសិទ្ធិមនុស្សមួយផ្នែកដែលមិនអាចដកហូតចេញបាន ដែលតាមរយៈសិទ្ធិនេះមនុស្សម្នាក់ៗក៏ដូចជាប្រជាជនអាស៊ានមានសិទ្ធិចូលរួម រួមចំណែក រីករាយ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌និងនយោបាយប្រកបដោយសមធម៌និងចីរភាព ។ សិទ្ធិទទួលបានការអភិវឌ្ឍត្រូវសម្រេចប្រកបដោយសមធម៌ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍនិងតម្រូវការបរិស្ថាន សម្រាប់មនុស្សជំនាន់នេះនិងពេលអនាគត ។ ខណៈដែលការអភិវឌ្ឍជួយសម្របសម្រួលនិងមានភាពចាំបាច់សម្រាប់ការអនុវត្តសិទ្ធិមនុស្ស កង្វះខាតនៃការអភិវឌ្ឍមិនត្រូវជាហេតុផលប្រើប្រាស់សម្រាប់ការរំលោភបំពានលើសិទ្ធមនុស្ស ដែលត្រូវបានអន្តរជាតិទទួលស្គាល់នោះទេ ។

៣៦. រដ្ឋជាសមាជិកអាស៊ានត្រូវអនុម័តយកកម្មវិធីអភិវឌ្ឍន៍ដែលផ្តោតសំខាន់លើប្រជាជន និងដែលឆ្លើយតបនឹងយេនឌ័រ សំដៅការកាត់បន្ថយភាពក្រីក្រ ការបង្កើតល័ក្ខខ័ណ្ឌនានាដូចជាការការពារនិងការរក្សានិរន្តភាពនៃបរិស្ថានសម្រាប់ប្រជាជនអាស៊ាន ដើម្បីទទួលបានសិទ្ធិមនុស្សទាំងឡាយដែលទទួលស្គាល់នៅក្នុងសេចក្តីប្រកាសនេះដោយផ្អែកលើមូលដ្ឋានសមធម៌ និងការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍនៅក្នុងអាស៊ានជាបន្តបន្ទាប់ ។

៣៧. រដ្ឋជាសមាជិកអាស៊ាន ទទួលស្គាល់ថាការអនុវត្តសិទ្ធិទទួលបានការអភិវឌ្ឍនេះ ទាមទារអោយមានគោលនយោបាយអភិវឌ្ឍប្រកបដោយប្រសិទ្ធិភាពនៅថ្នាក់ជាតិក៏ដូចជាទំនាក់ទំនងសេដ្ឋកិច្ចប្រកបដោយសមធម៌ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងបរិយាកាសសេដ្ឋកិច្ចអន្តរជាតិដែលមានលក្ខណៈគាប់ប្រសើរ ។ រដ្ឋជាសមាជិកអាស៊ានគួរបញ្ជ្រាបទិដ្ឋភាពពាក់ព័ន្ធច្រើនវិស័យនៃសិទ្ធិទទួលបានការអភិវឌ្ឍទៅក្នុងវិស័យពាក់ព័ន្ធនានាក្នុងការកសាងសហគមន៍អាស៊ាននិងបន្ទាប់ពីនេះ និងធ្វើកិច្ចការជាមួយសហគមន៍អន្តរជាតិដើម្បីលើកកំពស់ការអភិវឌ្ឍប្រកបដោយសមធម៌និងចីរភាព ការអនុវត្តន៍ពាណិជ្ជកម្មដ៏យុត្តិធម៌ និងកិច្ចសហប្រតិបត្តិការអន្តរជាតិប្រកបដោយប្រសិទ្ធិភាព ។

## សិទ្ធិទទួលបានសន្តិភាព

*៣៨. មនុស្សម្នាក់ៗ ក៏ដូចជាប្រជាជនអាស៊ាន មានសិទ្ធិទទួលបានសន្តិភាពនៅក្នុងក្របខណ្ឌអាស៊ានលើផ្នែកសន្តិសុខ និងស្ថេរភាព អព្យាក្រឹត្យភាពនិងសេរីភាព ដូចសិទ្ធិទាំងអស់ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ ត្រូវបានទទួលស្គាល់ទាំងស្រុង ។ ដូចនេះរដ្ឋជាសមាជិកអាស៊ានបន្តពង្រឹងមិត្តភាពនិងកិច្ចសហប្រតិបត្តការ ដើម្បីពង្រីកបន្ថែមនូវសន្តិភាព ភាពសុខដុមរមនា និងស្ថេរភាពនៅក្នុងតំបន់ ។*

## កិច្ចសហប្រតិបត្តការនៅក្នុងការលើកកម្ពស់និងការការពារសិទ្ធិមនុស្ស

*៣៩. រដ្ឋជាសមាជិកអាស៊ានចែករំលែកផលប្រយោជន៍រួមនិងប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សនិងសេរីភាជាមូលដ្ឋាន ដែលត្រូវសម្រេចបានតាមរយៈកិច្ចសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមក ក៏ដូចជាជាមួយអង្គការ ស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ ថ្នាក់តំបន់និងអន្តរជាតិជាដើម ស្របទៅតាមធម្មនុញ្ញអាស៊ាន ។*

*៤០. ពុំមានផ្នែកណាមួយនៃសេចក្តីប្រកាសនេះអាចត្រូវបានបកស្រាយសម្រាប់រដ្ឋ ក្រុម ឬបុគ្គល នូវសិទ្ធក្នុងការអនុវត្តសកម្មភាពណាដែលមានគោលបំណងធ្វើឱ្យប៉ះពាល់ដល់គោលបំណង និងគោលការណ៍របស់អាស៊ាន ឬក្នុងការបំផ្លិចបំផ្លាញនូវសិទ្ធិនិងសេរីភាពជាមូលដ្ឋាននានា ដែលបានកំណត់នៅក្នុងសេចក្តីប្រកាសនេះ និងនៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិនានាដែលរដ្ឋជាសមាជិកអាស៊ានជាភាគី ។*

*អនុម័តដោយប្រមុខរដ្ឋ/ប្រមុខរដ្ឋាភិបាលនៃរដ្ឋជាសមាជិកអាស៊ាន នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី ដប់ប្រាំបី នៃខែ វិច្ឆិកា ក្នុងឆ្នាំ ២០១២ ក្នុងសំណៅដើមតែមួយគត់ជាភាសាអង់គ្លេស ។*